| ១៩៥១. | ឃុំ ពេជសារ | - ដ - | ៧ នាក់ |
| ១៩៥២. | ឃុំ ព្រៃខ្លា | - ដ - | ៩ នាក់ |
| ១៩៥៣. | ឃុំ ព្រៃយុថ្កា | - ដ - | ៥ នាក់ |
| ១៩៥៤. | ឃុំ រមេញ | - ដ - | ៩ នាក់ |
| ១៩៥៥. | ឃុំ ធ្លាប្រជុំ | - ដ - | ៥ នាក់ |

**ស្រុកគិរីវង់**

| | | | |
|---|---|---|---|
| ១៩៥៦. | ឃុំ អង្គប្រាសាទ | ចំនួនសមាជិកក្រុមប្រឹក្សា | ៧ នាក់ |

| | | | |
|---|---|---|---|
| ១៥៥៧. | ឃុំ ព្រះបាទជាន់ជុំ | - ដ - | ១១ នាក់ |
| ១៥៥៨. | ឃុំ កំណាប់ | - ដ - | ៥ នាក់ |
| ១៥៥៩. | ឃុំ កំពែង | - ដ - | ៧ នាក់ |
| ១៥៦០. | ឃុំ គិរីចុងកោះ | - ដ - | ៥ នាក់ |
| ១៥៦១. | ឃុំ គោកព្រេច | - ដ - | ៩ នាក់ |
| ១៥៦២. | ឃុំ ភ្នំដិន | - ដ - | ៧ នាក់ |
| ១៥៦៣. | ឃុំ ព្រៃអំពក | - ដ - | ៧ នាក់ |
| ១៥៦៤. | ឃុំ ព្រៃរំដេង | - ដ - | ៩ នាក់ |
| ១៥៦៥. | ឃុំ រាមអណ្ដើក | - ដ - | ៥ នាក់ |
| ១៥៦៦. | ឃុំ សោម | - ដ - | ៧ នាក់ |
| ១៥៦៧. | ឃុំ តាអូរ | - ដ - | ៧ នាក់ |

**ស្រុកបុរីជលសារ**

| | | | |
|---|---|---|---|
| ១៥៦៨. | ឃុំ បុរីជលសារ | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៥៦៩. | ឃុំ ជ័យជោគ | - ដ - | ៥ នាក់ |
| ១៥៧០. | ឃុំ ដូងខ្ពស់ | - ដ - | ៥ នាក់ |
| ១៥៧១. | ឃុំ កំពង់ក្រសាំង | - ដ - | ៥ នាក់ |
| ១៥៧២. | ឃុំ គោកពោធិ៍ | - ដ - | ៧ នាក់ |

**ស្រុកគិរីវង់** 

| | | | |
|---|---|---|---|
| ១៥៧៣. | ឃុំ ចំបក់ | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៥៧៤. | ឃុំ ចំប៉ី | - ដ - | ៥ នាក់ |
| ១៥៧៥. | ឃុំ ដូង | - ដ - | ៧ នាក់ |
| ១៥៧៦. | ឃុំ កណ្ដឹង | - ដ - | ៧ នាក់ |
| ១៥៧៧. | ឃុំ កុមាររាជា | - ដ - | ៧ នាក់ |
| ១៥៧៨. | ឃុំ ក្រាំងលាវ | - ដ - | ៩ នាក់ |
| ១៥៧៩. | ឃុំ ក្រាំងធ្នង់ | - ដ - | ៧ នាក់ |
| ១៥៨០. | ឃុំ លំពង់ | - ដ - | ៧ នាក់ |
| ១៥៨១. | ឃុំ ពារាម | - ដ - | ៧ នាក់ |
| ១៥៨២. | ឃុំ ពត់សរ | - ដ - | ៩ នាក់ |

| | | | |
|---|---|---|---|
| ១៥៨៣. | ឃុំ សូភី | - ដ - | ៧ នាក់ |
| ១៥៨៤. | ឃុំ តាំងដូង | - ដ - | ៥ នាក់ |
| ១៥៨៥. | ឃុំ ត្នោត | - ដ - | ៧ នាក់ |
| ១៥៨៦. | ឃុំ ត្រពាំងក្រសាំង | - ដ - | ៧ នាក់ |
| ១៥៨៧. | ឃុំ ត្រពាំងសាប | - ដ - | ១១ នាក់ |

**ស្រុកអង្គរបូរី**

| | | | |
|---|---|---|---|
| ១៥៨៨. | ឃុំ អង្គរបូរី | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៥៨៩. | ឃុំ បាស្រែ | - ដ - | ៧ នាក់ |
| ១៥៩០. | ឃុំ គោកធ្លក | - ដ - | ៥ នាក់ |
| ១៥៩១. | ឃុំ ពន្លៃ | - ដ - | ៧ នាក់ |
| ១៥៩២. | ឃុំ ព្រែកផ្ទោល | - ដ - | ៥ នាក់ |
| ១៥៩៣. | ឃុំ ព្រៃផ្គាំ | - ដ - | ៩ នាក់ |

**ក្រុងដូនកែវ**

| | | | |
|---|---|---|---|
| ១៥៩៤. | សង្កាត់ បារាយណ៍ | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៥៩៥. | សង្កាត់ រកាក្នុង | - ដ - | ៩ នាក់ |
| ១៥៩៦. | សង្កាត់ រកាក្រៅ | - ដ - | ១១ នាក់ |

## ២២- ខេត្តកែប

**ស្រុកដំណាក់ចង្អើរ**

| | | | |
|---|---|---|---|
| ១៥៩៧. | ឃុំ អង្កោល | ចំនួនសមាជិកក្រុមប្រឹក្សា | ៧ នាក់ |
| ១៥៩៨. | ឃុំ ពងទឹក | - ដ - | ៧ នាក់ |

**ក្រុងកែប**

| | | | |
|---|---|---|---|
| ១៥៩៩. | សង្កាត់ កែប | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៦០០. | សង្កាត់ ព្រៃធំ | - ដ - | ៧ នាក់ |
| ១៦០១. | ឃុំ អូរក្រសារ | - ដ - | ៥ នាក់ |

## ២៣- ខេត្តប៉ៃលិន

**ស្រុកសាលាក្រៅ**

| | | | |
|---|---|---|---|
| ១៦០២. | ឃុំ សាលាក្រៅ | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៦០៣. | ឃុំ ស្ទឹងត្រង់ | - ដ - | ៧ នាក់ |

| | | | |
|---|---|---|---|
| ១៦០៤. | ឃុំ ស្ទឹងកាច់ | - ដ - | ៩ នាក់ |
| ១៦០៥. | ឃុំ អូរអណ្តូង | - ដ - | ៥ នាក់ |

**ក្រុងប៉ៃលិន**

| | | | |
|---|---|---|---|
| ១៦០៦. | សង្កាត់ ប៉ៃលិន | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៦០៧. | សង្កាត់ អូរតាវ៉ៅ | - ដ - | ៧ នាក់ |
| ១៦០៨. | សង្កាត់ ទួលល្វា | - ដ - | ៥ នាក់ |
| ១៦០៩. | សង្កាត់ បយ៉ាខា | - ដ - | ៥ នាក់ |

## ២៤- ខេត្តឧត្តរមានជ័យ

**ស្រុកអន្លង់វែង**

| | | | |
|---|---|---|---|
| ១៦១០. | ឃុំ អន្លង់វែង | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៦១១. | ឃុំ ត្រពាំងតាវ | - ដ - | ៥ នាក់ |
| ១៦១២. | ឃុំ ត្រពាំងប្រីយ៍ | - ដ - | ៧ នាក់ |
| ១៦១៣. | ឃុំ ថ្លាត | - ដ - | ៥ នាក់ |
| ១៦១៤. | ឃុំ លំទង | - ដ - | ៥ នាក់ |

**ស្រុកបន្ទាយអំពិល**

| | | | |
|---|---|---|---|
| ១៦១៥. | ឃុំ អំពិល | ចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ១៦១៦. | ឃុំ បេង | - ដ - | ៧ នាក់ |
| ១៦១៧. | ឃុំ គោកខ្ពស់ | - ដ - | ៥ នាក់ |
| ១៦១៨. | ឃុំ គោកមន | - ដ - | ៧ នាក់ |

**ស្រុកចុងកាល់**

| | | | |
|---|---|---|---|
| ១៦១៩. | ឃុំ ជើងទៀន | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៦២០. | ឃុំ ចុងកាល់ | - ដ - | ៧ នាក់ |
| ១៦២១. | ឃុំ ក្រសាំង | - ដ - | ៥ នាក់ |
| ១៦២២. | ឃុំ ពង្រ | - ដ - | ៥ នាក់ |

**ស្រុកត្រពាំងប្រាសាទ**

| | | | |
|---|---|---|---|
| ១៦២៣. | ឃុំ បាក់អន្លូង | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៦២៤. | ឃុំ ផ្លាវ | - ដ - | ៥ នាក់ |
| ១៦២៥. | ឃុំ អូរស្វាយ | - ដ - | ៥ នាក់ |

| | | | |
|---|---|---|---|
| ១៦២៦. | ឃុំ ព្រះប្រឡាយ | - ដ - | ៥ នាក់ |
| ១៦២៧. | ឃុំ ទំនប់ដាច់ | - ដ - | ៥ នាក់ |
| ១៦២៨. | ឃុំ ត្រពាំងប្រាសាទ | - ដ - | ៧ នាក់ |

**ក្រុងសំរោង**

| | | | |
|---|---|---|---|
| ១៦២៩. | សង្កាត់ បន្សាយរាក់ | ចំនួនសមាជិកក្រុមប្រឹក្សា | ៥ នាក់ |
| ១៦៣០. | សង្កាត់ បុស្សូរ | - ដ - | ៥ នាក់ |
| ១៦៣១. | សង្កាត់ កូនក្រៀល | - ដ - | ១១ នាក់ |
| ១៦៣២. | សង្កាត់ សំរោង | - ដ - | ១១ នាក់ |
| ១៦៣៣. | សង្កាត់ អូរស្មាច់ | - ដ - | ៧ នាក់ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥៤ . អនក្រ. បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនទីប្រឹក្សាបរទេស ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសវនកម្មជាតិ លើការងារបណ្តុះបណ្តាលមន្ត្រីរាជការ និងចងក្រងឯកសារពាក់ព័ន្ធការងារសវនកម្ម កន្លងមក ដូចមានខាងក្រោម ៖

| | |
|---|---|
| ១-លោក Juergen Lehmberg | ប្រធានក្រុមទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិ អាល្លឺម៉ង់ |
| ២-បណ្ឌិត Klaus Henning Busse | ទីប្រឹក្សាជាន់ខ្ពស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ អាល្លឺម៉ង់ ប្រចាំអាជ្ញាធរសវនកម្ម |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៩៥ ...

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនសប្បុរសជនជនជាតិកូរ៉េ ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយកសាងនិងគ្រប់គ្រងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកុំព្យូទ័រ និងសាលាភាសាបរទេស នៃកងយោធពលខេមរភូមិន្ទ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

១-លោក **លី យ៉ុងយៀល** (LEE JONG YEAL) ប្រធានក្រុមជុំនុំព្រះវិហារ ហេង ភុក ណាំទូម (PRESIDENT OF HANG PUK CHURCH )

២-លោក **យ៉ាន យុងហ្គូ** ( JEAN YOUNG GOOU ) អនុប្រធានក្រុមជុំនុំព្រះវិហារ ហេង ភុក ណាំទូម (VICE PRESIDENT OF HANG PUK CHURCH)

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៩២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១..**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ជូនក្រុមគ្រូពេទ្យរបស់មន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម និងមន្ទីរពេទ្យភ្នែកទីក្រុង ហូជីមិញ ចំនួន ០៧ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការនិងបានជួយវះកាត់ព្យាបាលភ្នែកឡើងបាយ ជូនកងទ័ព និងប្រជាជនក្រីក្រ កម្ពុជា ចំនួន១០ លើករួចមកហើយដូចមានរាយនាមខាងក្រោម:

**ក.មេដាយ សហមេត្រី ថ្នាក់ សេនា**

១. លោកវេជ្ជបណ្ឌិត វរសេនីយ៍ឯក **ប៊ុយ ស៊ុនហ៊ើប** (Colonel Bs BUI XUAN HOP) ប្រធានអគារកម្មាភិបាលជាន់ខ្ពស់A11 មន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជន វៀតណាម

២. លោកវេជ្ជបណ្ឌិត **ង្វៀន ដូង្វៀន** ( Ts NGUYEN DO NGUYEN ) ប្រធានអគារវះកាត់មន្ទីរពេទ្យ ក្រុង ហូជីមិញ

**ខ.មេដាយ សហមេត្រី ថ្នាក់ អស្សឫទ្ធិ**

១. លោកស្រីវរសេនីយ៍ត្រី **ក្វាន ត្រាងតូ** ( Major QUAN TRANG TO ) គ្រូពេទ្យមធ្យមអគារភ្នែក មន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

២. លោកស្រី **ង្វៀន ធីថាញ់** ( Mrs. NGUYEN THI THANH ) គ្រូពេទ្យមធ្យមអគារភ្នែកមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

៣. លោកស្រី **ផាម** **ធីខាញ់** (Mrs. PHAM THI KHANH) គ្រូពេទ្យមធ្យមអគារភ្នែក មន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

៤. លោកស្រី **ដាំង** **ធីភឿងធៀន** (Mrs. DANG THI PHUONG THIEN) គ្រូពេទ្យមធ្យម អគារភ្នែកមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជន វៀតណាម

៥. លោកស្រី **ឡេង** **ធីង៉ុកង៉ា** (Mrs. LENG THI NGOC NGA) គ្រូពេទ្យមធ្យមអគារ ភ្នែកមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

**មាត្រា២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនឯកឧត្តម **នៃ្ត សុខណ្ណារ៉ា** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ និងជានាយខណ្ឌរដ្ឋបាលព្រៃឈើកណ្តាល ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួនជួយកសាងស្រះទឹក០១កន្លែង មានបណ្តោយ ៥០ម៉ែត្រ ទទឹង៣០ម៉ែត្រ ជម្រៅ៤.៥ម៉ែត្រ និងធ្វើជណ្តើរចំនួន០២ សម្រាប់ចុះទៅក្នុងស្រះ ជូនប្រជាពលរដ្ឋក្នុងសហគមន៍ព្រៃឈើ **លាភគុយ** ស្ថិតនៅក្នុងឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ **ចំណាយអស់ថវិកាសរុបចំនួន ១២.៥០០ ដុល្លារ ។**

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៩៩៨ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុញ្ញាតអោយមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ ១១៦ អនក្រ.តត ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលអោយស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១** : ត្រូវបានអនុញ្ញាតឱ្យលោក **អ៊ឹម សុទ្ធី** ប្រធានផ្នែកទទួលបន្ទុកច្បាប់ពាណិជ្ជកម្ម និងធុរកិច្ចនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល ០២ ឆ្នាំ លើកទី៣ គិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៣។

**មាត្រា ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៩៩៩ . អនក្រ . បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគធនធានចូលរួមអភិវឌ្ឍន៍មូលដ្ឋាន និងជួយកសាង កុដិ ០១ខ្នង ក្លោងទ្វារវត្ត ហោត្រៃយ៍ ០១ខ្នង សាលាឆទាន ០១ខ្នង ផ្លូវបេតុង ០១ខ្សែ វច្ចកុដិ ០២បន្ទប់ បង្គោលភ្លើង ២៧ដើម រូបសំណាក២ ជួលជុលបល្ល័ង្ក និងសាលាបាលី ស្ថិតនៅវត្តល្វាសរ ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | ស្រឿន ផន | ព្រះគ្រូចៅអធិការស្តីទី វត្តល្វាសរ |
| ២- | លោក | អ៊ុំ រិន | ប្រធានគណៈកម្មការអាចារ្យវត្តល្វាសរ |
| ៣- | ឧបាសិកា | គង់ យឹម | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៤- | អ្នកស្រី | សុខ យ៉ាន | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៥- | អ្នកស្រី | សុខ ចិន្តា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៦- | អ្នកស្រី | យឹម សឿមអាត | សប្បុរសជននៅរាជធានីភ្នំពេញ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១.សណន**

## សេចក្តីណែនាំ

## ស្តីពីការចាត់តាំងរៀបចំខួប២០ឆ្នាំ នៃការយាងនិវត្តន៍មកកាន់មាតុភូមិវិញ នៃព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ, ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ ក្នុងគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា និងទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា

ក្នុងស្មារតីផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ និងតាមសំណើសុំយាងរបស់គណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាល នៃអតីតរដ្ឋកម្ពុជា **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងនិវត្តន៍មកកាន់មាតុភូមិវិញ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ក្រោយពីព្រះអង្គទាំងទ្វេ បានគង់ប្រថាប់ នៅបរទេសអស់រយៈពេល ២០ ឆ្នាំ គឺជាការចាប់ផ្តើមបដិសន្ធិ ព្រះរាជាណាចក្រកម្ពុជាលើកទី២ឡើងវិញ។ គិតមកដល់ឆ្នាំ ២០១១ នេះ គឺមានរយៈពេល ២០ឆ្នាំគត់។ ម្យ៉ាងទៀត **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ព្រះអង្គទ្រង់ប្រសូត នៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំចត្វាស័ក ព.ស.២៤៦៦ ត្រូវនឹងថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩២២ ដែលនឹងត្រូវប្រារព្ធព្រះរាជពិធីបុណ្យចម្រើន ព្រះជន្មថ្វាយព្រះអង្គ ក្នុងគម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា ក្នុងរូបភាពមហោឡារិក ខុសប្លែកពីឆ្នាំធម្មតា ។

កន្លងមកក៏ដូចជាបច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាតែងដង្ហែតាមព្រះរាជតម្រិះដ៏ថ្លៃថ្លា របស់ព្រះអង្គជារៀងរហូត និងតែងបានសំដែងមនោសញ្ចេតនា គោរពស្រឡាញ់ក្នុងទឹកចិត្ត ប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និងស្មោះត្រង់បំផុត ចំពោះព្រះអង្គជាព្រះបិតា ឯករាជ្យជាតិ ផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ ។

ស្របទៅនឹងសភាពការណ៍ចំពោះមុខ ដែលព្រះរាជាណាចក្រកម្ពុជា នឹងត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា. បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ ២០១២ និងការបោះឆ្នោតសកលឆ្នាំ ២០១៣ ខាងមុខ, ការប្រារព្ធខួប ២០ឆ្នាំ នៃការយាងធ្វើមាតុភូមិនិវត្តន៍របស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ និងការប្រារព្ធព្រះរាជពិធី

បុណ្យចម្រើនព្រះជន្មក្នុងគម្រប់ ៨៩ យាងចូល៩០ព្រះវស្សា ថ្វាយព្រះអង្គ និងទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្នុងរូបភាពមួយដ៏មហោឡារិក គឺជាហេតុផលដ៏សក្តិសមដែលមានប្រយោជន៍យ៉ាងច្រើន ដល់សង្គមជាតិទាំងមូល ។

ដើម្បីសម្រេចនូវគោលបំណង និងសំណូមពរនៃការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យទាំងបី រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើសេចក្តីណែនាំមួយចំនួនដូចតទៅនេះ :

១-ក្រសួងព្រះបរមរាជវាំង ចាត់តាំងរៀបចំព្រះរាជពិធីទាំងបី នៅក្នុងព្រះបរមរាជវាំង តាមប្រពៃណីសាសនា និង ប្រពៃណីជាតិ តាមការសព្វព្រះរាជហឫទ័យរបស់**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ។

២-ក្រសួងពត៌មាន ផ្សព្វផ្សាយរាល់រូបភាពស្តីពីព្រះរាជសកម្មភាពរបស់ **ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង**សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈ តាមវិទ្យុ ទូរទស្សន៍ បណ្តាញពត៌មាន ឱ្យបានទូលំទូលាយ ចាប់ពីដើមរៀងមករហូតដល់បច្ចុប្បន្ន ។

៣-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គ្រប់ស្ថានទូត ស្ថានកុងស៊ុល និងស្ថានតំណាងបេសកកម្មអចិន្ត្រៃយ៍ ធ្វើការផ្សព្វផ្សាយទូលាយ និងរៀបចំចាត់តាំងពិធីបុណ្យខាងលើឱ្យបានសមរម្យ ដោយមានអញ្ជើញភ្ញៀវ អន្តរជាតិចូលរួម ។

៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងសំដែងសិល្បៈបូរាណ សម័យ ជូនមហាជនទស្សនាកំសាន្ត រយៈពេល២យប់ គឺយប់នៃថ្ងៃទី៣១ ខែតុលា និងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ តាមទីតាំងកំណត់ ។

៥-រាជធានីភ្នំពេញ និងគ្រប់ខណ្ឌ ត្រូវរៀបចំមហាមីទ្ទិញមួយដោយមានការចូលរួមគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងមាន ប្រជាពលរដ្ឋ ចូលរួមដ៏មហោឡារិក ដោយមានដោតទង់ជាតិ ទង់ផ្កាឈូក ទង់ក្អែប បដា ពាក្យស្លោក ប៉ាណូតូច-ធំ សារលិខិតថ្វាយព្រះពរ និងមានបាញ់កាំជ្រួច ។

៦-គ្រប់ខេត្ត ក្រុង ស្រុក ត្រូវរៀបចំធ្វើមីទ្ទិញមហាជនមួយ ដែលមានថ្នាក់ដឹកនាំ និងគ្រប់សមាសភាពមហាជនចូលរួម នៅទីតាំងសមរម្យ តាមការជាក់ស្តែង តាមទីកន្លែងនីមួយៗ ដោយមានការតុបតែងលម្អដោតទង់ជាតិ ទង់ក្អែប បដា ពាក្យស្លោក ប៉ាណូ តាមទីតាំងកំណត់ ។

៧-គ្រប់ក្រសួង ស្ថាប័នរដ្ឋ រាជធានី និងគ្រប់ខេត្ត ត្រូវរៀបចំតាំងពិព័រណ៍រូបភាព ស្តីពីព្រះរាជសកម្មភាពរបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង**សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈ ក្នុងព្រះរាជបេសកកម្មដើម្បីបុព្វហេតុជាតិ និងប្រជារាស្ត្រ និងស្តីពីសមិទ្ធផលសំខាន់ៗ គ្រប់វិស័យដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននៅទីលានវាលព្រះមេរុ ដើម្បីបង្ហាញ ជូនទស្សនិកជនជាតិ-អន្តរជាតិ ទស្សនាស្វែងយល់ជាប្រវត្តិសាស្ត្រ ។

៨-កាលបរិច្ឆេទនៃការប្រារព្ធពិធី នឹងត្រូវប្រព្រឹត្តទៅរយៈពេល១ថ្ងៃ គឺថ្ងៃចន្ទ ទី៣១ ខែតុលា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ និងគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងទូទាំងប្រទេស ។ ឯការតាំងពិព័រណ៍រូបភាព ត្រូវប្រព្រឹត្តទៅនៅទីលានវាលព្រះមេរុ រាជធានីភ្នំពេញ ចាប់ថ្ងៃទី៣១ ខែតុលា ដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលជាថ្ងៃ

៤

ប្រារព្ធទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា, ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដើម្បីទុកជូនមហាជន ប្រជាជនជាតិ អន្តរជាតិ ចូលទស្សនា។

៩-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ ថវិកា សម្រាប់បម្រើការរៀបចំព្រះរាជពិធីទាំងបីខាងលើ ឱ្យបានសក្តិសមនិងទាន់ពេលវេលា។

១០-គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវធ្វើផែនការណែនាំលំអិត និងបង្កើតគណៈ-កម្មការ អន្តរក្រសួងមួយ ដើម្បីទទួលរៀបចំព្រះរាជពិធីទាំងបីនេះ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត ត្រូវចាត់តាំងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៣៧០៤ ឧ.រ.ថ..ព.ក.ម.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៥៧០ /១១ គ.វ.ក ចុះថ្ងៃទី១៥.០៧.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ិ-ហ្សេត អ៊ិនធើណេសិនណល ហ្គាមេន ហ្វេកធើរី ចុះថ្ងៃទី ០៦.០៧.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ិ-ហ្សេត អ៊ិនធើណេសិនណល ហ្គាមេន ហ្វេកធើរី តំណាងដោយ លោកស្រី CHEN LINGYAN សញ្ជាតិចិន អាយុ២៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខG47557335 ចុះថ្ងៃទី០៩.១២.២០១០ មានអាសយដ្ឋានបច្ចុប្បន្នៈ Pun Dong Shang3 Road Sangkat Zhijiang Khan Xiansan, HanZhuo City, China. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤១ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ៨៥៥ -២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh Phone 855-23-211141, Fax 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *"អ៊ី-ហ្សេត អ៊ិនធើណេសិនណល ហ្គាមេន ហ្វេកធើរី"*

*"(E-Z INTERNATIONAL GARMENT FACTORY CO., LTD. )"*

**ទីតាំងរោងចក្រ ៖** *"ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២.** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាពព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**<u>ប្រការ១១:</u>** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**<u>ប្រការ១២:</u>** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**<u>ប្រការ១៣:</u>** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**<u>ប្រការ១៤:</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**<u>ប្រការ១៥:</u>** ប្រកាសនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**<u>ចម្លងជូន:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៧៤០៣ ឧរថ.កស.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៥៤២ /១១ គ.វ.ក ចុះថ្ងៃទី១៣.០៧.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វីនសុន អ៊ិនធល ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២១.០៦.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន វីនសុន អ៊ិនធល ហ្គាមេន (ខេមបូឌា) អិលធីឌី តំណាងដោយ លោក YEUNG LUNG CHAU សញ្ជាតិចិន អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ K01308309 ចុះថ្ងៃទី០៨.០៩.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ Unit 1404, Eastern Harbour Center, 28 Hoi Chak Street, Quarry Bay, Hong Kong ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *" វីនសុន អ៊ិនថល ហ្គាមេន (ខេមបូឌា) អិលធីឌី "*

*"(WINSON INT' L GARMENT (CAMBODIA) LTD. )"*

**ទីតាំងរោងចក្រ៖** *" ផ្លូវជាតិលេខ៤ ភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

__ប្រការ២:__ -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

__ប្រការ៣:__ -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

__ប្រការ៤:__ ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

__ប្រការ៥:__ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

__ប្រការ៦:__ ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្ដល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្ដល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្ដល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ដល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្ដល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្ដីណែនាំអំពីស្ដង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

រាជធានីភ្នំពេញ, ថ្ងៃទី..២០..ខែ..កក្កដា..ឆ្នាំ ២០១១

លេខ:...១៩០ វ.ក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងអាជីវកម្ម សេវាកម្មសម្លាងការ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពី រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅ គ្រប់គ្រងនិងណែនាំលើអាជីវកម្ម សេវាកម្មសម្លាងការ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណង ដើម្បីការពារ និង ថែរក្សានូវទំនៀមទម្លាប់ប្រពៃណី និងអត្តសញ្ញាណជាតិឲ្យបានគង់វង្ស។

**ប្រការ ២.-**

ម្ចាស់អាជីវកម្ម សេវាកម្មសម្ពាងការ ត្រូវគោរពទៅតាមរបៀបរបបដែលទាក់ទងទៅនឹងការរៀបចំពិធីមង្គលការជាប្រពៃណីរបស់ជាតិ។

ការប្រើប្រាស់សម្លៀកបំពាក់អាពាហ៍ពិពាហ៍តាមប្រពៃណី ត្រូវគោរពតាមខ្នាតនិងពណ៌សម្បុររបស់ជាតិនិងត្រូវអនុវត្តទៅតាមពេលវេលានៃការរៀបចំពិធីនីមួយៗ។

គ្រឿងអលង្ការជាប្រពៃណីដែលប្រើប្រាស់ក្នុងការតាក់តែងកាយ ត្រូវគោរពទៅតាមបែបបទនិងទម្រង់របស់ជាតិ។

រាល់ដំណើរការក្នុងពិធីមង្គលការតាមប្រពៃណីជាតិ ម្ចាស់សម្ពាងការ ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ ៣.-**

ម្ចាស់សម្ពាងការ ត្រូវមានកម្មវិធីនិងឧបករណ៍សម្ភារៈចាំបាច់ដែលជាតម្រូវការក្នុងការរៀបចំពិធីមង្គលការ។ ករណីគ្មាន ត្រូវពិភាក្សាជាមួយម្ចាស់ដើមពិធីជាមុនដើម្បីរកវិធីដោះស្រាយ។

**ប្រការ ៤.-**

ការផ្លាស់ប្តូរសម្លៀកបំពាក់ កូនកម្លោះ ក្រមុំ ក្នុងពិធីជប់លៀងមង្គលការ ញឹកញាប់ ដែលនាំឲ្យបាត់បង់ទំនៀមទម្លាប់និងសុជីវធម៌ជាតិ ត្រូវហាមឃាត់។

**ប្រការ ៥.-**

រាល់ការច្នៃប្រឌិតណាមួយ ដែលនាំឲ្យប៉ះពាល់ដល់ការបាត់បង់នូវលក្ខណៈដើមនៃប្រពៃណីជាតិ ត្រូវហាមឃាត់។

**ប្រការ ៦.-**

ការបើកទីតាំងអាជីវកម្ម សេវាកម្មសម្ពាងការ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត ឬ តាមការិយាល័យច្រកចេញចូលតែមួយនៃ ក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

រាល់ការអនុញ្ញាតបើកទីតាំងអាជីវកម្ម សេវាកម្មសម្ពាងការ ត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយនៃ ក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បទស្សនីយភាព ប្រធាននាយកដ្ឋានអភិវឌ្ឍវប្បធម៌ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធនិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ:.....[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី..២៧..ខែ..កក្កដា..ឆ្នាំ ២០..១១

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មសៀវភៅ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១**: ប្រកាសនេះមានគោលបំណងគ្រប់គ្រងអាជីវកម្មនិងសេវាកម្មសៀវភៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សៀវភៅ សំដៅកម្រងក្រដាសដែលមានបោះពុម្ពអក្សរ ឬនិងរូបភាព មានទំហំនិងកម្រាស់តាមសាច់រឿងដែលសរសេររៀបរាប់នូវរឿងរ៉ាវផ្សេងៗ មានក្របខាងក្រៅ មានចំណងជើង និងមានអ្នកនិពន្ធជាម្ចាស់កម្មសិទ្ធ។

**ប្រការ២**: ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសិទ្ធិពិនិត្យលើខ្លឹមសារអត្ថបទអក្សរសាស្ត្រ អក្សរសិល្ប៍ និង រូបភាពគ្រប់បែបយ៉ាងដែលមានលើទំព័រសៀវភៅទាំងអស់ ក្នុងគោលបំណងដើម្បីថែរក្សា ការពារនិងលើកតម្កើងវប្បធម៌ជាតិ។

រាល់ខ្លឹមសារសៀវភៅដែលនិយាយមិនល្អ ប៉ះពាល់ដល់ព្រះកិត្តិនាមព្រះមហាក្សត្រ ជំនឿសាសនា វប្បធម៌វីរបុរសជាតិ ការរើសអើងជាតិសាសន៍ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈត្រូវហាមឃាត់។

**ប្រការ៣**: ខ្លឹមសារដែលមានចែងក្នុងប្រការ ២ មិនសំដៅដល់សៀវភៅគ្រប់ប្រភេទ ដែលបោះពុម្ពដោយស្ថាប័នជំនាញក្នុងទិសដៅអប់រំសិក្សា មិនធ្វើអាជីវកម្ម ហើយដែលជាសមត្ថកិច្ចរបស់ស្ថាប័ននោះជាអ្នកទទួលខុសត្រូវ។

ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ប្រការ៤**: គ្រប់សៀវភៅទាំងអស់ដែលបោះពុម្ព ដាក់លក់តាមបណ្ណាគារ ឬតាមគ្រប់ទីតាំងអាជីវកម្មលក់សៀវភៅត្រូវមានបញ្ជាក់ឈ្មោះអ្នកនិពន្ធ ចំនួនបោះពុម្ព ឈ្មោះរោងពុម្ព និងចុះលេខសៀវភៅតាមខ្នាតអន្តរជាតិ( ISBN )។

**ប្រការ៥**: សៀវភៅគ្រប់ប្រភេទ ដែលជាស្នាដៃរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងបោះពុម្ពដើម្បី គោលដៅអាជីវកម្ម ទោះក្នុងបែបផែនអ្វីក៏ដោយត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ក្នុងករណីចាំបាច់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអាចស្នើសុំក្រសួងពាក់ព័ន្ធដើម្បីសហការ។

**ប្រការ៦**: ដើម្បីងាយស្រួលសម្គាល់ជាម្ចាស់កម្មសិទ្ធិ ម្ចាស់ស្នាដៃតែងនិពន្ធសៀវភៅគ្រប់ប្រភេទ ត្រូវសុំចុះបញ្ជីរក្សាសិទ្ធិស្របច្បាប់នៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៧**: ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាម្ចាស់កម្មសិទ្ធិលើស្នាដៃតែងនិពន្ធសៀវភៅគ្រប់ប្រភេទដែលគ្មានមតិកសាសន៍ ។ រាល់ការយកស្នាដៃគ្មានមតិកសាសន៍ទៅបោះពុម្ព ផ្សព្វផ្សាយត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៨**: សៀវភៅគ្រប់ប្រភេទជាភាសាជាតិ និងភាសាបរទេស ដែលយកទៅធ្វើអាជីវកម្មតាមបណ្ណាគារ ទីតាំងអាជីវកម្មលក់សៀវភៅក្នុងទីផ្សារ ឬ តាមទីសាធារណៈ ត្រូវតែជាសៀវភៅដែលមានចុះបញ្ជីរក្សាសិទ្ធិអ្នកនិពន្ធត្រឹមត្រូវ។

**ប្រការ៩**: បណ្ណាគារ ទីតាំងអាជីវកម្មលក់សៀវភៅ ក្នុងទីផ្សារ ឬតាមទីសាធារណៈ មិនត្រូវបានអនុញ្ញាតឲ្យយកសៀវភៅថតចម្លងមកដាក់លក់ក្នុងកន្លែងធ្វើអាជីវកម្មរបស់ខ្លួន។

**ប្រការ១០**: ការបើកបណ្ណាគារ ឬ ទីតាំងអាជីវកម្ម លក់សៀវភៅគ្រប់ប្រភេទ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ឬតាមការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការប្រកបអាជីវកម្ម នាំចេញ នាំចូល សៀវភៅគ្រប់ប្រភេទ ត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ១១**: រាល់ការអនុញ្ញាតធ្វើអាជីវកម្ម និងសេវាកម្មសៀវភៅត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខណ្ឌ ស្រុកគោលដៅ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ១២**: នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសៀវភៅ និងការអាន ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ហ៊ឹម_ឆែម

កន្លែងទទួល:

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ